From
the People of Japan

គជអប
NCDD

WFP
World Food
Programme

សម្រាប់ការចេញផ្សាយបន្ទាន់

# រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន២លានដុល្លារដល់កម្មវិធីស្បៀងអាហារពិភពលោក ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារទឹកជំនន់ទៅលើសន្តិសុខស្បៀង

**រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១៖** រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយជាថវិកាចំនួន២លានដុល្លារអាមេរិកដល់កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារទឹកជំនន់ទៅលើសន្តិសុខស្បៀងរបស់ក្រុមគ្រួសារនិងសហគមន៍រងគ្រោះដោយសារទឹកជំនន់នៅកម្ពុជា។

កិច្ចព្រមព្រៀងផ្តល់ជំនួយនេះត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ រវាង ឯកឧត្តម MIKAMI Masahiro ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកស្រី Claire CONAN ជាតំណាង និងជានាយកប្រចាំប្រទេសនៃកម្មវិធីស្បៀងអាហារពិភពលោក ក្រោមអធិបតីភាពនិងការចូលរួមជាសាក្សីដោយ ឯកឧត្តម ង៉ាន់ ចំរើន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

ឯកឧត្តម Mikami Masahiro ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍ថា «កាលពីឆ្នាំមុន ប្រទេសកម្ពុជាបានទទួលរងនូវភ្លៀងធ្លាក់យ៉ាងខ្លាំងជាបន្តបន្ទាប់ ដែលប៉ះពាល់ដល់ប្រជាជនមួយចំនួនធំ ក៏ដូចជាបង្កឲ្យមានការបាត់បង់ជីវិតនិងការខូចខាតផ្នែករូបវ័ន្តទៅលើទ្រព្យសម្បត្តិជាច្រើន។ ខ្ញុំមានក្តីសង្ឃឹមដោយស្មោះថា គម្រោងនេះនឹងកាត់បន្ថយផលប៉ះពាល់ទៅលើសន្តិសុខស្បៀងរបស់ក្រុមគ្រួសារនិងសហគមន៍ដែលរងគ្រោះដោយទឹកជំនន់»។

នៅក្នុងគម្រោងនេះ កម្មវិធីស្បៀងអាហារពិភពលោកនឹងសហការយ៉ាងជិតស្និទ្ធជាមួយ គ.ជ.អ.ប និងដៃគូនានា ដើម្បីធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងតំបន់រងគ្រោះដោយទឹកជំនន់និងគាំទ្រដល់ការស្តារសហគមន៍ឡើងវិញតាមរយៈការស្តារហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត និងការពង្រឹងសមត្ថភាពធ្វើផែនការ និងចំណេះដឹងមូលដ្ឋានស្តីពីសន្តិសុខស្បៀង ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះមហន្តរាយ។ គម្រោងនេះបានកំណត់គោលដៅនៅក្នុងឃុំចំនួន១៦ នៅក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ធំ។

លោកស្រី **Claire CONAN** តំណាងកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជាបានលើកឡើងថា «យើងខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុនដែលបានគាំទ្រដល់កិច្ចការកាត់បន្ថយផលប៉ះពាល់ដោយសារទឹកជំនន់កាលពីឆ្នាំមុន។ ជំនួយនេះមានសារៈសំខាន់ណាស់សម្រាប់ក្រុមគ្រួសារងាយរងគ្រោះដែលរស់នៅក្នុងសហគមន៍ដែលងាយជន់លិចដោយ

ទឹកជំនន់ ដែលប៉ះពាល់ទៅលើជីវភាពនិងប្រព័ន្ធស្បៀងរបស់ពួកគាត់ ហើយជំនួយនេះនឹងជួយការពារពួកគាត់ពីវិបត្តិនាពេលអនាគត» ។

ក្នុងអំឡុងពេលមួយទសវត្សកន្លងមកនេះ ប្រទេសកម្ពុជាបានរងផលប៉ះពាល់ដោយសារទឹកជំនន់ធ្ងន់ធ្ងរចំនួន៤លើក។ លើកចុងក្រោយបង្អស់នៅក្នុងខែតុលាឆ្នាំមុន ទឹកជំនន់បានបង្កឱ្យក្រុមគ្រួសារចំនួន១៤.២៩៩គ្រួសារផ្លាស់ប្តូរទីលំនៅ និងប៉ះពាល់ដោយផ្ទាល់ទៅលើក្រុមគ្រួសារចំនួន១៧៦.០០០គ្រួសារ (ជិត ៨០០.០០០ នាក់) ក្នុងខេត្តចំនួន១៤។ លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងដីកសិកម្មរងការជន់លិចនិងខូចខាតយ៉ាងដំណំ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៦ ក្នុងចំណោមប្រទេសទាំង១៨១ នៅក្នុងសន្ទស្សន៍ហានិភ័យពិភពលោកឆ្នាំ២០២០ ដែលកំណត់ទៅលើភាពងាយរងគ្រោះខ្ពស់ដោយសារគ្រោះមហន្តរាយធម្មជាតិ។ វិបត្តិផ្នែកអាកាសធាតុដូចជាទឹកជំនន់និងគ្រោះរាំងស្ងួតកើតមានជាញឹកញាប់នៅតាមសហគមន៍ ហើយកំណើននិងកម្រិតនៃគ្រោះមហន្តរាយនេះទំនងជានឹងកើនឡើងនាពេលអនាគត ដោយសារឥទ្ធិពលនៃការផ្លាស់ប្តូរអាកាសធាតុនិងការបាត់បង់ធនធានធម្មជាតិ ដែលប៉ះពាល់ដល់សហគមន៍ក្រីក្រមួយចំនួន។

ចាប់តាំងពីឆ្នាំ១៩៩៨មក រដ្ឋាភិបាលជប៉ុនគឺជាដៃគូដ៏សំខាន់របស់កម្មវិធីស្បៀងអាហារពិភពលោក ដែលបានចូលរួមវិភាគទានចំនួន២២លានដុល្លារអាមេរិកក្នុងអំឡុងពេល១០ឆ្នាំកន្លងមកនេះតាមរយៈជំនួយជាសម្ភារៈ (អង្ករ និងត្រីកំប៉ុង) និងជំនួយជាទឹកប្រាក់ ក្នុងការគាំទ្រលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ នៅឆ្នាំ២០១៩ ប្រទេសជប៉ុនបានចូលរួមវិភាគទានចំនួន២,៧លានដុល្លារអាមេរិកដល់កម្មវិធីស្បៀងអាហារពិភពលោក ដើម្បីលើកកម្ពស់កសាងភាពធន់របស់សហគមន៍នៅកម្ពុជាដើម្បីទប់ទល់នឹងវិបត្តិ និងកសាងសមត្ថភាពស្ថាប័នក្នុងការត្រៀមលក្ខណៈទប់ទល់នឹងគ្រោះអាសន្ន។ ជំនួយគាំទ្រនេះបានបង្កើតនូវសមិទ្ធិផលចំនួនបីគឺ ទី១) ការសាងសង់មជ្ឈមណ្ឌលជម្លៀសពីទឹកជំនន់ចំនួន៦ នៅក្នុងខេត្តចំនួន៣ ដែលងាយរងគ្រោះដោយទឹកជំនន់ ទី២) ការពង្រឹងផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ និង ទី៣) ការលើកកម្ពស់ការចាត់វិធានការទាន់ពេលវេលាតាមរយៈប្រព័ន្ធប្រកាសអាសន្នជាមុន។

**#######**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖ លោកស្រី ជា ជូ
មន្ត្រីផ្នែកទំនាក់ទំនងនិងរបាយការណ៍
កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា
ទូរស័ព្ទលេខ៖ **+855 78 565 283**
អ៊ីម៉ែល៖ **chou.chea@wfp.org**